# សេចក្តីថ្លែងការណ៍

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ អំពាវនាវសុំរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ធ្វើច្បាប់ហាមការប្រកបមុខរបរស្រីពេស្យា

Website: www.hoksavann.org

ថ្ងៃទី៦ ធ្នូ ២០០៤

នៅក្នុងពេលថ្មីៗនេះ អាជ្ញាធរខ្មែរបានប្រកាសបិទបនស្រីពេស្យានៅតំបន់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ សូមអនុមោទនាការបិទនេះ ព្រោះតំបន់នេះមានឈ្មោះអាក្រក់បំផុតក្នុងការប្រព្រឹត្តអំពើអបាយមុខនេះ ។

ការបិទនេះ គ្រាន់តែបន្ថយចំនួនមនុស្សកើតរោគអេដ៍បានមួយចំនួនតូចប៉ុណ្ណោះ ព្រោះបិទតំបន់នេះអាចទៅបង្កើតតំបន់ផ្សេងទៀត ដូច្នេះដើម្បីបន្ថយរោគអេដ៍ឲ្យបាន១០០ភាគរយ សូមអំពាវនាវរាជរដ្ឋាភិបាលខ្មែរសូមធ្វើច្បាប់ហាមការប្រកបមុខរបរស្រីពេស្យានេះតែម្តង បើជនណាប្រព្រឹត្តខុសច្បាប់នេះ សូមផ្តន្ទាទោសតាមច្បាប់ដូចសហរដ្ឋអាមេរិកនិងប្រទេសកាណាដាជាដើម បានអនុវត្តបែបនេះតាំងពីដើមមក គឺបើមានមនុស្សប្រកបមុខរបរនេះប៉ូលិសតែងតែតាមចាប់ ។

យើងពុំយល់ស្របថា ការចែកស្រោមអនាម័យអាចនឹងបំបាត់រោគអេដ៍បានឡើយ ប៉ុន្តែវិធីនេះគ្រាន់តែជំរុញឲ្យបុរសដែលមានប្រពន្ធហើយនិងបុរសដែលពុំទាន់មានប្រពន្ធ ទៅប្រព្រឹត្តអំពើកាមគុណកាន់តែច្រើនឡើងៗប៉ុណ្ណោះ ។ ដើម្បីដោះស្រាយឲ្យដល់ឫសគល់ កុំឲ្យកើតមានរោគអេដ៍បន្តទៅទៀត មានតែវិធីធ្វើច្បាប់ហាមវិជ្ជាជីវៈស្រីពេស្យានេះ ហើយធ្វើទោសចំពោះអ្នកប្រព្រឹត្តខុស ទោះបីអ្នកនោះមានបុណ្យស័ក្តិខ្ពស់យ៉ាងណាក៏ដោយ ព្រោះតាមពត៌មានបនស្រីពេស្យាតែងមានបង្អែកយ៉ាងមាំពីអ្នកកាន់អំណាចខ្មែរ ។

ក្រៅពីច្បាប់ផ្តន្ទាទោសចំពោះអ្នករត់ពន្ធស្ត្រីនិងកុមារឲ្យធ្វើជាស្ត្រីពេស្យាចារ សូមពាវនាវរាជរដ្ឋាភិបាលខ្មែរធ្វើច្បាប់មួយទៀត ផ្តន្ទាទោសដល់ម្តាយឪពុកនិងអាណាព្យាបាល ដែលលក់កូនស្រីរបស់ខ្លួនឲ្យគេយកទៅធ្វើជាស្រីពេស្យា ឬលក់ឲ្យអ្នកធំមានអំណាច ឬអ្នកមានទ្រព្យសម្បត្តិ ដែលគេយកទៅគ្រាន់តែបំពេញសេចក្តីសប្បាយខាងកាមគុណរបស់គេប៉ុណ្ណោះ ។ ការលក់កូននេះ ចាត់ទុកថាម្តាយឪពុកគ្មានព្រហ្មវិហារធម៌ដល់កូន ដោយបានបំផ្លាញអនាគតរបស់កូន ផ្ទុយពីធម៌របស់ព្រះពុទ្ធ ហើយនាំឲ្យខូចប្រពៃណីទំនៀមទំលាប់ដ៏ល្អរបស់ខ្មែរផង ។ មិនត្រឹមតែធ្វើច្បាប់ផ្តន្ទាទោសដល់ម្តាយឪពុកដែលលក់កូនស្រីរបស់ខ្លួនទេ សូមធ្វើច្បាប់ផ្តន្ទា- ទោសដល់អ្នកទិញដូរ គឺអ្នកមានអំណាចទាំងនោះផង ។

អ្នកដែលចេះតែទៅប្រព្រឹត្តកាមគុណនៅខាងក្រៅផ្ទះនេះ មកពីមានផ្ទះបន បើគ្មានច្បាប់បង្កើតផ្ទះបនទេ នោះក៏គ្មានអ្នកប្រព្រឹត្តកាមគុណបែបនេះដែរ ហើយក៏គ្មានរោគអេដ៍ឆ្លងតទៅទៀតដែរ, ក្នុងសិក្ខាបទទីបីនៃនៃសីល៥របស់ព្រះពុទ្ធសាសនាបានបង្រៀនមនុស្សឲ្យមានការសន្តោសក្នុងផ្លូវកាមគុណ គឺបុរសនិងស្ត្រីជាប្តីប្រពន្ធត្រូវមានចិត្តត្រង់នឹងគ្នាកុំក្បត់ចិត្តគ្នា ទៅរកស្រីឬបុរសដទៃទៀត គឺកុំលួចប្រពន្ធប្តីនិងកូនអ្នកដទៃ ។ ដើម្បីឲ្យសិក្ខាបទព្រះពុទ្ធនេះក្លាយជាការអនុវត្តន៍ សូមផ្លូវអាណាចក្រជួយពង្រឹងខាងផ្លូវច្បាប់ឲ្យបានតឹងតែង ចំពោះអ្នករំលោភលើប្រពន្ធលើកូនអ្នកដទៃ ហើយតុលាការសូមផ្តល់យុត្តិធម៌ជូនអ្នករងគ្រោះ ។

មុខរបរសំរាប់ធ្វើឲ្យប្រទេសចំរើនលូតលាស់មានច្រើនណាស់ គួរតែចៀសវាងមុខរបរស្រីពេស្យានេះ ព្រោះមុខរបរនេះព្រះពុទ្ធបានហាមថា ជាអំពើអបាយមុខ ជាប្រធាននៃសេចក្តីវិនាស ។ ដោយប្រទេសកម្ពុជាជាប្រទេសគោរពព្រះពុទ្ធសាសនា គួរតែធ្វើតាមឱវាទរបស់ព្រះពុទ្ធ គឺវៀរចាកមុខរបរស្រីពេស្យា ដែលជាមុខរបរផ្ទុយពីសេចក្តីចំរើននេះ ព្រោះជាមុខរបរនាំឲ្យខូចសុខភាពដល់សាមីខ្លួនអ្នកប្រព្រឹត្តផង មានបញ្ហាដល់សង្គមក្នុងការចំណាយការព្យាបាលផង ហើយជាពិសេសនាំឲ្យកើតជម្លោះក្លាយជាអំពើហឹង្សា ដោយការដណ្តើមស្នេហាគ្នា មានការចាក់ទឹកអាស៊ីដដាក់គ្នាជាដើម ។ រដ្ឋមិនត្រូវចង់បានតាក់បន្តិចបន្តួចដែលបានមកពីផ្ទះបន ហើយធ្វើឲ្យជីវិតមនុស្សរាប់សែននាក់ត្រូវស្លាប់ដោយសាររោគអេដ៍នេះឡើយ ។ មនុស្សជាធនធាននៃសង្គមមានតម្លៃជាងប្រាក់កាស ។

រដ្ឋមានមុខនាទីជាចាំបាច់ក្នុងការលើកតំកើងជីវភាពរបស់ប្រជាពលរដ្ឋឲ្យខ្ពង់ខ្ពស់ ដោយបំបាត់ភាពក្រីក្របង្កើតមុខរបរដែលឥតទោសឲ្យប្រជាពលរដ្ឋធ្វើ កុំឲ្យប្រជាពលរដ្ឋងាកទៅរកមុខរបរដែលព្រះពុទ្ធហាមមានមុខរបរស្រីពេស្យានេះជាដើម ។ រោគអេដ៍ជាសង្គ្រាមឥតប្រកាសកំពុងមានចលនានៅប្រទេសកម្ពុជាយ៉ាងខ្លាំងក្លា ដែលកើតមានតាំងពីសម័យអ៊ុនតាក់ឆ្នាំ១៩៩១មកម្ល៉េះ គឺអ៊ុនតាក់របស់អង្គការសហប្រជាជាតិនេះហើយដែលនាំយកជម្ងឺអេដ៍មកចម្លងដល់ប្រជាពលរដ្ឋខ្មែរ ។ ប្រពន្ធនិងកូនដែលឥតដឹងអ្វីសោះក៏ត្រូវទទួលរោគអេដ៍ ដោយសារប្តីនិងឪពុកនាំយកមកពីផ្ទះស្រីបន ដូច្នេះត្រូវតែធ្វើច្បាប់បំបាត់ផ្ទះបន ។ រោគអេដ៍សម្លាប់ប្រជាពលរដ្ឋខ្មែរ បើពុំមានវិធីបំបាត់ឲ្យទាន់ពេលវេលាទេប្រជាពលរដ្ឋខ្មែរនឹងត្រូវស្លាប់ជាងវាលពិឃាតខ្មែរក្រហមទៅទៀត។ ការបំបាត់រោគអេដ៍ មធ្យោបាយមានតែមួយ គឺធ្វើច្បាប់ហាមមុខរបរស្រីបនពេស្យានេះឯង ។ រដ្ឋត្រូវឧបត្ថម្ភដោយបង្កើតការបង្រៀនវិជ្ជាជីវៈនិងរកការឲ្យស្រីដែលចេញពីបនស្រីពេស្យាធ្វើ ហើយស្រីណាដែលមានជម្ងឺត្រូវឲ្យចូលក្នុងមន្ទីរពេទ្យព្យាបាលជម្ងឺផង ។៚